(រូបថតកម្មសិទ្ធិក្អួយលោកអូឈៀងនាម កែវ វីរៈនៅកាណាដា)

អូ ឈៀង (អូ ឈាង)

AU Chhieng

(1908-1992)

ដោយបណ្ឌិតសភាចារ្យ **ឃីង ហុកឌី**

អូឈៀង កើតថ្ងៃទី២៤ កុម្ភៈ ១៩០៨ នៅទីរួមខេត្ត បាត់ដំបងក្នុងភូមិ វត្តគរ ផ្នែកខាងស្តាំស្ទឹងសង្កែ នៅជិត គេហដ្ឋាន

គហបតី « សោ ហឺ »ដែលសព្វថ្ងៃនៅក្នុងបរិវេណវត្តកណ្តាល[1]។ បិតានាម«**ស៊ូ អូ**»[2] និងមាតានាម «**អ៊ុកប៊ុល**»[3]។

ខេត្តបាត់ដំបង គ្រប់គ្រងដោយក្រុមគ្រួសារត្រកូលអភ័យវង្សជាច្រើនទសវត្សរ៍ ហើយស្តេចត្រាញ់ចុងក្រោយគឺលោកម្ចាស់ « **ឈុំ** »។[4]

ការសិក្សានៅកម្ពុជា៖

ដោយគ្មានឯកសារបង្ហាញពីការសិក្សាកុមារ **អូឈៀង** នៅ

---

[1] Cf. Grégory Mikaelian, « Le Grû du Parnasse : Au Chhieng chez les Titans », *Péninsule* n° 78- 2019 (1), p. 96-97. ពត៌មានមួយចំនួនយកចេញអត្ថបទរបស់បណ្ឌិតហ្រ្គេហ្គោរីមិីគេលីយ៉ង់ដែលចែងក្នុងអត្ថបទស្រាវជ្រាវនេះ។

[2] មានកូន៤នាក់គឺប្រុស២នាក់និងស្រី២នាក់៖ អូ ឈឿន, អូ ឈៀង, នាង អូ វៀង និងនាង អូ វឿយ (ម្តាយ កែវ វីរៈ នៅកាណាដាសព្វថ្ងៃ)។ ប្រភពពី កែវ វីរៈ ត្រូវជាក្មួយបង្កើតសាស្រ្តាចារ្យ អូ ឈៀង។

[3] សូមអានបន្ថែមABDOUL-CARIME Nasir, « Au Chhoeun », *AEFEK*, Hommes et Destins, http://www.aefek.fr/wa.files/au_chhoeun_2pdf.

[4] សូមអានបន្ថែម តួចឈួង, បាត់ដំបង សម័យលោកម្ចាស់, ភ្នំពេញ, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ, ១៩៩៤,២៣៣ ទំព័រ។សៀវភៅនេះមានបកប្រែជាភាសាអង់គ្លេស បោះផ្សាយនៅហូណូលូលូឆ្នាំ១៩៩៤៖ TAUCH Chhuong, *Battambang during the time of the Lord Gorvernor*, Translated by Hin Sithan, Carol Mortland and Judy Ledgerwood, Publications Funded by East West Center, Honolulu Hawaii, 1994,143 p. ។ សូមអានអត្ថបទដែលសរសេរដោយឡុចឆានឆៃ ជាភាសាបារាំង៖ LOCH Chhanchhai, « Chronique des vice-rois de Battambang (XVIIIe-XXI siècles) : du règne Bèn de Battambang à la famille Aphawong du Siam », *Péninsule* n° 68 – 2014 (1), pp. 9-103.

បឋមសិក្សា តែយើងអាចស្មានថាប្រហែលជាបានសិក្សានៅវត្ត អារាមក្បែរគេហដ្ឋានមាតាបិតាគឺនៅវត្តសង្កែហើយនៅសម័យ នោះគឺនៅក្រោមឥទ្ធិពលប្រទេសសៀមហើយបានទទួលការសិក្សា ភាសាសៀមជាការចាំបាច់នេះមិនខានឡើយ។ បើតាមយល់កុមារ **អូឈៀង** ប្រហែលដើរតាមគន្លងបងប្រុស នាម **អូ ឈឿន** ដែល បានសិក្សានៅសាលាបឋមសិក្សា បារាំងមានពីរនៅក្រុងបាត់ដំបង មុននឹងបានចូល អនុវិទ្យាល័យព្រះស៊ីសុវត្ថិនៅក្រុងភ្នំពេញ។

តាមបណ្ណសារអាណានិគមបារាំងឆ្នាំ១៩២២ បែងថា កុមារ **អូឈៀង** បានចូលរៀននៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ដោយបានទទួលអាហារូបករណ៍រស់នៅក្នុងសាលានេះមាន ជន្មាយុ១៤ឆ្នាំ។ នាពេលនោះបងប្រុសនាម **អូ ឈឿន** បាន ចេញពីអនុវិទ្យាល័យព្រះស៊ីសុវត្ថិដោយបានរៀនចប់ នាឆ្នាំ បន្ទាប់ ហើយយុវជន **អូ ឈឿន** បានប្រឡងចូលសាលាច្បាប់ និងរដ្ឋបាលនៅក្រុង ហាណូយ ប្រទេសយៀកណាម។ ក្នុង រយៈ៤ឆ្នាំនៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ យុវជន **អូ ឈៀង** បានទំនាក់ទំនងនឹងសិស្សនានាដែលថ្ងៃក្រោយមកក្លាយជា វរជនជាតិសំខាន់ៗដូចជា៖

អៀវកើស ដែលមានកំណើតនៅខេត្តបាត់ដំបងដូចគ្នា,
ម៉ុងតេយ៉ូ, **ញឹកជូឡុង**, **សុងរឹងសៃ** ជាដើម។

ការសិក្សានៅហាណូយប្រទេសវៀតណាមនិងនៅប៉ារីសប្រទេសបារាំង៖

បន្ទាប់ពីរៀនចប់ នៅអនុវិទ្យាល័យព្រះស៊ីសុវត្ថិ អស់រយៈ៤ឆ្នាំមក យុវជន **អ៊ូឈៀង** បានបន្តការសិក្សានៅសាលាគរុកោសល្យក្នុងក្រុងហាណូយ។ដល់២ឆ្នាំក្រោយមកទៀត បានបញ្ចប់ការសិក្សានៅទីនោះហើយបានទទួលការតែងតាំងក្នុងក្របខណ្ឌសាស្ត្រាចារ្យបម្រុងចាប់តាំងពីខែកញ្ញា ១៩២៩ ហើយបានទទួល ពេញសិទ្ធិជាសាស្ត្រាចារ្យបង្រៀនបឋមឧត្តមបារាំង-អន្តោគ្រាម (professeur de l’enseignment primaire supérieur franco-indigène) នៅខែមករា១៩៣១[5]។ បន្ទាប់មកក្នុងឆ្នាំដដែលនេះយុវជន **អ៊ូឈៀង** បានមកបំពេញវិជ្ជានៅប្រទេសបារាំងហើយបានសំណាក់នៅគេហដ្ឋានឥណ្ឌូចិនក្នុងបុរីអន្តរជាតិនៃសាកលវិទ្យាល័យក្រុងប៉ារីស។

នៅប៉ារីស យុវជន**អ៊ូឈៀង** បានសិក្សាភាសាសំស្ក្រឹតនិងពីវិជ្ជាផ្សេងៗទាក់ទងនឹងវប្បធម៌អរិយធម៌ឥណ្ឌាទៀតពី

---

[5] បណ្ណសារជាតិកម្ពុជា RS 16456 – Collège Sisowath. Rapport mensuels, 1929-1932 ; RS 25357 – Concours de recrutement des élèves du collèges Sisowath -1930.

អ្នកប្រាជ្ញបារាំងធំៗ ដូចជាសាស្ត្រាចារ្យល្បីៗនៅសម័យនេះ មាន ស៊ីលវ៉ាំងឡេវី (Sylvain Lévi), អាលហ្វ្រេតហ្វូហ្សេរ (Alfred Foucher), លុយី រ៉ើនូ (Louis Renou) ជាដើម។ និក្ខេបបទពីសិលាចារឹកខ្មែរធ្វើជាមួយសាស្ត្រាចារ្យស៊ីលវ៉ាំងឡេវី (Sylvain Lévi) មិនបានចប់ដោយគ្រូអាចារ្យដឹកនាំរបស់លោកស្លាប់។ អាហារូបករណ៍ចប់អស់សុពលភាព រដ្ឋអំណាចអាណាព្យាបាលបារាំងនៅកម្ពុជាកោះហៅលោកទៅភ្នំពេញវិញ។ តែភ័ព្វល្អ លោកនាយករង៍ខុទ្ទកាល័យ រដ្ឋមន្ត្រីក្រសួងអាណានិគមបានជួយការពារ ដោយជួយរកការងារឲ្យលោក អ៊ូឈៀង ធ្វើជាសាស្ត្រាចារ្យថ្នាក់ទី១នាខែវិច្ឆកា១៩៣៧នៅសាលាជាតិប្រទេសបារាំងឯនាយសមុទ្រ (Ecole nationale de la France d’Outre-Mer, ENFOM) នៅក្រោមការ គ្រប់គ្រងរដ្ឋបាលអាណានិគម។ ចាប់ពីពេលនោះមកលោក អ៊ូឈៀង បានបន្តការសិក្សាច្បាប់ហើយបានប្រឡងជាប់បរិញ្ញាប័ត្រច្បាប់ឆ្នាំ១៩៣៨។ បន្ទាប់មកទៀតបានប្រឡងជាប់សញ្ញាប័ត្រជាន់ខ្ពស់ច្បាប់ (DES) នៅឆ្នាំ១៩៣៩។ ក្រោយពីបានទទួលសញ្ញាប័ត្រទាំងនេះមកលោកបានផ្តើមស្រាវជ្រាវនិងសរសេរនិក្ខេបបទបណ្ឌិតច្បាប់។

បន្ទាប់ក្រោយមកនាឆ្នាំ១៩៤១មានលោកអូឈៀង៍ក៏បានសរសេរនិក្ខេបបទមួយចប់ដែរពីអាណាព្យាបាលបារាំងដែល ខុសច្បាប់ ។ នេះជាហេតុធ្វើឲ្យរដ្ឋអំណាចនគរបាលបារាំងក្រុងប៉ារីសហាមមិនបានឲ្យនិក្ខេបបទនេះចេញផ្សាយនៅសម័យក្រោមការ ត្រួតត្រាបារាំងដោយរដ្ឋអំណាចបារាំងយល់ថា **និក្ខេបបទនេះ** ជា**បទវិទ្ធង្សន**ាប្រឆាំងនឹងរដ្ឋបាលអាណានិគមបារាំងនៅកម្ពុជា។ ក្រសួងនគរបាលក្រុងប៉ារីសបានប្រមូលច្បាប់ បោះពុម្ព និក្ខេបបទនេះកម្ទេចចោល ទាំងអស់ៗតែភ័ព្វល្អ និក្ខេបបទនេះនៅសល់ខ្លះៗ គឺឃើញមានសល់១ច្បាប់នៅបណ្ណាល័យមហាវិទ្យាល័យច្បាប់នៅខេត្ត«ប៉ូ» (Pau) និង១ច្បាប់ទៀតនៅបណ្ណាល័យមហាវិទ្យាយច្បាប់ខេត្តអាមីញេង (Amiens) តែអ្នកអានមិនអាច ធ្វើកូពីចម្លងបានទេ។ ហេតុនេះបានជាថតជារូបថតតែទំព័រមុខជាឯកសារសិន។ បន្ទាប់មកបានថតជារូបថត១ទំព័រម្តងៗដើម្បីកុំឲ្យខូចច្បាប់ដើមដែលបណ្ណាល័យខំរក្សាទុកជាយូរមកហើយ។

នៅចន្លោះពេលនោះលោកអូឈៀង៍បានជួបនារីបារាំងម្នាក់នៅក្រុងប៉ារីសនាម ហ្សាកឡូតវ៉ាស៊ែរ (Charlotte Wasser)ហើយបានការនឹងនាងនោះនៅខែមេសា

១៩៣៩។[6] *ប្រហែលចាប់ពីពេលនោះមកដែលលោក* **អូឈៀង** *បានចាកចេញពីបុរីសាកលវិទ្យាល័យអន្តរជាតិក្រុងប៉ារីសពីគេហដ្ឋាន ឥណ្ឌូចិន ទៅស្នាក់នៅផ្ទះ១នៅជាយក្រុងប៉ារីសគឺនៅ ហ្សាទើណេម៉ាឡាព្រី* (Châtenay-Malabry)[7] *ដែលមានដីនៅជុំវិញផ្ទះ។*

ដោយនិក្ខេបបទនេះមានគំនិតប្រឆាំងនឹងអាជ្ញាធម៌អាណាព្យាបាលបារាំងៗមិនបានប្រគល់សញ្ញាប័ត្របណ្ឌិតច្បាប់ឲ្យលោក **អូឈៀង** *ទេ។ លោកមិនបានត្រឡប់ទៅរស់នៅភ្នំពេញវិញឡើយ គឺលោកមានគ្រួសារបារាំងនៅប៉ារីសហើយបានសិក្សាភាសាសំស្ក្រឹត រហូតដល់បានធ្វើជាសាស្ត្រាចារ្យបង្រៀនភាសាសំស្ក្រឹតនៅសាលាអនុវត្តន៍សិក្សាជាន់ខ្ពស់* (Ecole Pratique des Hautes Etudes à Ve section: histoire et philologie à la Sorbonne «*សាលាអនុវត្តន៍សិក្សាជាន់ខ្ពស់ផ្នែកប្រវត្តិសាស្ត្រនិងនិរុត្តិសាស្ត្រ*»)*។ លោកបាន*

---

6 *តាមការស្រាវជ្រាវរបស់* Grégory Mikaelian, « Le Grû du Parnasse : Au Chhieng chez les Titans », *Péninsule* n° 78- 2019 (1)។

7 *ពេលលោកឌុករ៉ាស៊ី (នៅរវាងឆ្នាំ១៩៤៦និង១៩៥៧)*មក*រៀនច្បាប់ដំបូងបានទៅជួបលោកអូឈៀងនៅគេហដ្ឋានលោក ឃើញមានចិញ្ចឹមមាន់ក្នុងទីធ្លាផ្ទះ។ តាមសារលោកឌុករ៉ាស៊ី ឆ្នាំ២០១៩។ ក្រោយមកនាឆ្នាំ១៩៧៣ លោកនិងគ្រួសារត្រឡប់មកនៅប៉ារីស៍វិញជិតមិត្តអ្នកស្រាវជ្រាវ។*
នេះកន្លែងចុងក្រោយរបស់លោកគឺ៖ Boulevard Saint-Michel- Paris *នៅក្បែរសាកលវិទ្យាល័យហ៊្សរបោន។*

ជួយធ្វើការបកប្រែសិលាចារឹកដល់សាស្ត្រាចារ្យ ហ្ស៊កសឺដេស (George Coedès) (*សូមអានសិលាចារឹកភាគ៣*[8] *និង ភាគ៨របស់សាស្ត្រាចារ្យ ហ្ស៊កសឺដេស*)[9] *ហើយលោកបានធ្វើ កាតាឡុក ជាបញ្ជីសាស្ត្រាខ្មែរនានាដែលរក្សាទុកនៅបណ្ណាល័យជាតិប្រទេសបារាំង។*

ការងារស្រាវជ្រាវនិងបង្រៀន៖

សន្និសិទ នៅហ្ស៊របោន ចុងក្រោយលោកគឺនៅឆ្នាំ១៩៨៤[10] *ដែលជាឆ្នាំដែលលោកបានត្រូវចូលនិវត្តន៍ទៅហើយ ព្រោះនៅប្រទេសបារាំង បុគ្គលិកក្រសួងអប់រំត្រូវបញ្ចប់ការងារយ៉ាងយូរគឺក្នុងអាយុ៦៥ឆ្នាំ ត្រូវតែចូលនិវត្តន៍ហើយទទួលប្រាក់សោធនរៀងរាល់ខែ។*

---

[8] *សូមអានបន្ថែម៖* G. COEDES, *Inscriptions du Cambodge*, volume III, Paris, E. de Boccard, 1961, p.1-2 : « La mise au point du présent volume a bénéficié de l’aide précieuse qu’a bien voulu m’apporter M. Au Chhieng, chargé de cours à ‘l’Ecole nationale de la France d’Outre-mer. Je lui dois mainte suggestion heureuse pour l’interprétation d’anciens mots disparus de la langue moderne. Je le remercie très cordialement de son amicale collaboration. »

[9] *សូមអានបន្ថែមអត្ថបទស្រាវជ្រាវ៖* Grégory Mikaelian, « Le Grû du Parnasse : Au Chhieng chez les Titans », *Péninsule* n° 78- 2019 (1), *ទំព័រ៩៣ដល់១៤២។*

[10] *សូមអានបន្ថែម* Bernard-Philippe GROSLIER, « L’image d’Angkor dans la conscience khmère », *Seksa khmer*, vol.n°8-9, 1986, pp. 27-28.

សាស្ត្រាចារ្យ អូ ឈៀង មានសិស្សគណជាច្រើនដែល ក្រោយមកក្លាយជាអ្នកស្រាវជ្រាវនិងជាសាស្ត្រាចារ្យដ៏ខ្ពង់ខ្ពស់ ដូចជា៖

កូឡែតកៃយ៉ា, ព្យែរស៊ីលវ៉ាំងហ្វីលីយ៉ូហ្សា, ហ្ស៊ីណែតតេរាល, ម៉ាកទីនព្យ៉ាត, ព្យែរប៊ីតា, កាមលេវារ ភត្តឆារ្យា, សាហៃ សាឆិដានន្ទ , សាវរសពៅ (Collette CAILLAT Pierre-Sylvain FILLIOZAT, Ginette TERRAL, Martine PIAT, Pierre BITARD , Kamalewar BHATTACHARYA, Sahai SACHIDANAND, Saveros POU)។

ក្នុងការស្រាវជ្រាវអ្នកប្រាជ្ញខ្មែរ រូបនេះបានបន្សល់សៀវភៅដ៏សំខាន់បំផុត១ នេះគឺ »កាតាឡុងឯកសារខ្មែរនៅបណ្ណាល័យជាតិប្រទេសបារាំង»[11] ដែលយើងអ្នកសិក្សាក្នុងខេមរវិទ្យា ទុកស្នាដៃនេះ ជាគម្ពីរ ដែលយើងត្រូវការ ជារៀងមក។

សាស្ត្រាចារ្យ អូ ឈៀង ទទួលបានអនិច្ចកម្មនៅថ្ងៃ ២៧ មិនា ១៩ ៩២ ក្នុងជន្មាយុ ៨៤ឆ្នាំ ក្នុងគ្រឹះស្ថានព្យាបាលមនុស្សចាស់ «ហ្វូរស៊ីយេស» (Forcilles)[12]។

ស្នាដៃជាសៀវភៅនិងអត្ថបទស្រាវជ្រាវ៖

JA : Journal Asiatique

[11] AU Chhieng, *Catalogue du fonds khmer, Paris*, Imprimerie nationale, 1953, 307 p.

[12] Cf. Grégory Mikaelian, « Le Grû du Parnasse : Au Chhieng chez les Titans», *Péninsule* n° 78- 2019 (1), p.119, note 91 : « Acte de Au Chhieng ». Il décède dans la maison médicalisée de Forcilles, à Forcilles-Atilly, en Seine-et-Marne.

- *Fondement du deuxième traité de protectorat français sur le Cambodge*, Paris, Domat-Monchrestien, 1941, xxxii-274 p.
- « Ecriture khmère ou cambodgienne », [*in*] *Notices sur les caractères étrangers*, Paris, 1948, pp. 307-316.
- Bloch Jules, Filliozat, Jean, Renou, Louis, *Canon bouddhique pâli. Tipitaka :* texte original en caractères cambodgiens (mul) avec traduction cambodgienne en regard. Suttapitaka Dighanikaaya, t. I, fasc. I, transcription de MM. Au Chhieng et Thach X'uong, Paris, Adrien Maisoneuve, Office de la recherche scientifique d'Outre-Mer, 1949, VII-97 p.
- *Catalogue du fonds khmer*, Paris, Imprimerie nationale, 1953, 307 p.
- Note additionnelle transmise à J. Filliozat et publiée à la fin de son article « Le symbolisme du monument du Phnom Bàkhèn », *BEFEO*, t. 44, n°2, 1951. pp. 527-554., pp. 553-554. (nom du Pākheṅ ; orientation symbolique présevée à l'époque moderne).
- « Etudes de philologie indo-khmère. I. L'association des idées littéraires dans les stances sanscrites de l'inscription de Sodk Kak Thoṃ et la place, dans cette inscription, de la stance CXXIX ; II. L'énoncé de la date en chiffre 1623 çaka dans la grande inscription d'Angkor Vat », *Journal asiatique (JA)*, n° 250 (4), 1962, pp. 575-591.
- « Etudes de philologie indo-khmère. III. L'indo-européen $*g^{w}\breve{\bar{o}}w$- vu à travers le khmer ; IV. Un changement de toponyme ordonné par Jayavarman III », *JA*, n° 254 (1), 1966, pp. 143-161.
- « Etudes de philologie indo-khmère. V. A propos de la statue dite du 'roi lépreux' », *JA*, n°256, 1968, pp. 185-201.
- « Etudes de philologie indo-khmère. VI. Une sentence du Cambodge moderne étudiée dans le prolongement de la culture indo-khmère du Cambodge ancien », *JA*, année 1971, pp. 297-308.
- « Etudes de philologie indo-khmère. VII. Un acte arbitraire et injuste du sanscrit classique redressé dans l'ancien Cambodge par le khmer », *JA*, n° 262 (1-2), 1974, pp. 131-136.
- « Etudes de philologie indo-khmère. VIII. Un récit ethnographique sur le "popil" », *JA*, n° 262 (1-2), 1974, pp. 137-141.
- « "Ban" et "Rnoc", deux thèmes de réflexion méthodologique pour l´étude du vieux-khmer », [*in*] *Mélanges d'indianisme à la mémoire de Louis Renou.* 40e anniversaire de la fondation de l'Institut de civilisation indienne de Paris 1967, Paris, Boccard, pp. 43-51 ;
- « Le nom posthume du roi cambodgien Suramarit, mort en 1960 (du présent vers le passé) », *JA*, CCLXXII, 1984 (3-4), pp. 395-401



(រូបថត កម្មសិទ្ធិ Grégory Mikaelian)

និក្ខេបបទច្បាប់ជាសៀវភៅនេះក្រសួង នគរបាលក្រុងប៉ារីសបានប្រមូលដុតចោលអស់។ តែភ័ព្វល្អនៅសេសសល់២ទៀត ដែលបានតម្កល់រក្សាទុកនៅបណ្ណាល័យមហាវិទ្យាច្បាប់នៅខេត្ត គឺ១ នៅ ខេត្ត ប៉ូ (PAU-BU Droit, cote UDT1110) និងមួយទៀតនៅខេត្ត អាមីញេង (AMIENS-BU Droit, cote SIB 463)។

AU Chhieng, Fondement du deuxième traité de protectoratfrançais sur le Cambodge, Paris, Dormat-Monchrestein, XXXII + 274 p.



កាតាឡុក ឯកសារខ្មែរនៅបណ្ណាល័យជាតិប្រទេសបារាំង
ដោយសាស្ត្រាចារ្យ **អូ ឈៀង** *(រូបថតយហឱ)។*

AU Chhieng, *Catalogue du fonds khmer*, Paris, Imprimerie Nationale, 1953, 307 p.

ឧបសម្ព័ន្ធ

ឯ.ឌ. អូឈឿង (១៩០៣-១៩៨៦)[13]៖

ក្រោយសង្គ្រាមលោកលើកទី២ នាឆ្នាំ១៩៤៦ បញ្ញជនខ្មែរដែលបានទទួលការសិក្សាចប់នៅប្រទេសបារាំងត្រឡប់ចូលភ្នំពេញវិញ គឺមាន ទ្រង់ស៊ីសុវត្ថិយុត្តិវង្ស និង លោកឈាមវ៉ម ជាដើម។ ចាប់តាំងពីពេលនោះមក មានការផ្ដើម តាក់តែង រដ្ឋធម្មនុញ្ញៗនេះបានប្រកាសឲ្យប្រើការនៅថ្ងៃទី៦ឧសភា១៩៤៧ ដែលជារដ្ឋធម្មនុញ្ញ«របបសភានិយម»។ បក្សនយោបាយបានផ្ដើមកើតរីកដុះដាលជាច្រើន។ ស្ដេចបីអង្គក៏បានបង្កើតគណបក្សដែរ គឺ ទ្រង់នរោត្តមនរិន្ទដេត មាននិន្នាការរាជានិយមហៅថា«គណបក្សសេរីភាព», ទ្រង់ នរោត្តមម៉ុងតាណា សហការជាមួយ ឯ.ឌ. អូឈឿង *ដែលមាននិន្នាការចម្រើននិយមមានឈ្មោះ ថា«គណបក្សប្រជាធិបតេយ្យចម្រើនជាតិ», ទ្រង់ស៊ីសុវត្ថិ យុត្តិវង្ស បង្កើតគណ*

[13] Cf .CORFIEL Justin & SUMMERS Laura, *Historical Dictionary of Cambodia*, The Scarecro Press, Lanham, 2003, p.23 : *អ្នកសរសេរទាំង២នាក់នេះឲ្យកាលបរិច្ឆេទខុស (១៩០៨ - ១៩៧៥)។ ត្រូវកែថា (១៩០៣ - ១៩៨៦) វិញទើបត្រឹមត្រូវ។*

បក្សមួយមានឈ្មោះថា«គណបក្ស ប្រជាធិតេយ្យ» ដែលមាន លោក ឈានវ៉ែម ជាអគ្គលេខាធិការ។[14]

បងប្រុសសាស្ត្រាចារ្យ អូឈៀង នាម ឯ.ឧ. អូឈឿន បានធ្វើជា ទីប្រឹក្សាជាន់ខ្ពស់ព្រះរាជបល្ល័ង្ក (២៤វិច្ឆកា១៩៥៣), ឆ្នាំ ១៩៥៤បានទទួលការតែងតាំងជាអគ្គរាជទូតប្រទេសកម្ពុជាប្រចាំ ក្រុងឡុង ប្រទេសចក្រភពអង់គ្លេស ហើយ បានត្រឡប់មកធ្វើអគ្គ រាជទូតប្រទេសកម្ពុជានាក្រុងឡុងម្តងទៀតនៅឆ្នាំ ១៩៥៩ក្រោយពី រឿងអាស្រូវ ជុំវិញ អគ្គរាជទូត សមសារី។ ឯ.ឧ. អូឈឿនបាន ចេញពីក្របខណ្ឌក្រសួងការបរទេសនាឆ្នាំ១៩៦៥។

ឯ.ឧ. អូឈឿន បានទទួលតួនាទីជារដ្ឋមន្ត្រីនៅកម្ពុជាជា ច្រើនដងច្រើនគ្រាក្នុងរដ្ឋាភិបាលនានា។ ឯកសារមួយចំនួនបានពី លោករ៉ូបេរ្តិ៍ ហេង (Robert HENG)ត្រូវជាចៅប្រុសឯ.ឧ. អូ ឈឿន បានផ្តល់ឲ្យ។ សូមថ្លែងអំណរគុណចំពោះសមានចិត្តលោក។ [15]

---

[14] សូមអានបន្ថែម៖ PRESCHEZ Philippe, *Essai sur la démocratie au Cambodge*, Paris, Fondation Nationale des Sciences Politiques, Série C : Recherches, n°4 1961, 234 p. ; DEVILLERS Philippe, FISTIE Pirre et al., *L'asie du Sud-Est*, Paris Sirey, 1971, p. 599 : «On vit alors se constituer officiellement le parti libéral du prince Norideth, un parti progressiste du prince Montana, et surtout, début mai, un parti démocrate, dont le prince Youthevong prit la tête, avec Chheam Vam comme secrétaire général… »

[15] Cf. PHOUK Chhay, *Les élites khmère*, thèse de doctorat en droit, Faculté de droit de Phnom Penh, 1966 ; CHAU Seng, *Les élites khmères*, Phnom Penh, Université bouddhique Preah Sihanouk Raj, Coll. Culture et Civilisations khmères, 1965.

នៅសម័យសាធារណរដ្ឋខ្មែរ សេនាប្រមុខ លន់នល់ បានតែងតាំង ឯ.ឧ. **អូ ឈឿន** ជាទីប្រឹក្សាផ្ទាល់ជាន់ខ្ពស់នាឆ្នាំ១៩៧២ ដល់១៩៧៣)។

ឯ.ឧ. **អូឈឿន**បានទទួលអនិច្ចកម្មនាឆ្នាំ១៩៨៦ ក្នុងជន្មាយុ ៨៣ឆ្នាំ នៅគេហដ្ឋានលោកនាក្រុងប៉ារីស។

រូបថតជុំវិញឯ.ឧ. អូឈឿន៖

ពីឆ្វេងទៅស្តាំ៖
ឯ.ឧ. អូ ឈឿន, សម្តេចក្រុមហ្លួង ព្រះស៊ីសុវត្ថិ មុនីពង្ស, សម្តេចឧបយុវរាជ ព្រះនរោត្តមសីហនុ



ពីឆ្វេងទៅស្តាំ៖ ឯ.ឧ. អូ ឈឿន (ឈរទី៣) នៅខាងឆ្វេង សម្តេចឧបយុវរាជ
ព្រះនរោត្តមសីហនុ (១៩៥៩)

៦.៩. អូ ឈឿន និង ជំទាវ អូតបុប្ផាវណ្ណ

បណ្ណសមាជិក

លេខ ២៥២

គោត្តនាមនិងបកតិនាម អ៊ូ ~ ឈឿន

សញ្ជាតិ ខ្មែរ កំណើតពីឆ្នាំ ១៩០៣

ក្របខណ្ឌដើម អគ្គរដ្ឋទូត កម្ពុជា

ថ្ងៃចូលសមាគម ទី ២៧ ខែមករា ឆ្នាំ១៩៦៧

នាមភរិយា~~ស្វាមី~~ នាគ - អ៊ូត - បុប្ផាវណ្ណ

អាសយដ្ឋាន លេខ ៣៨៥ មហាវិថីព្រះមុនីវង្ស

ក្រុងភ្នំពេញ

ភ្នំពេញថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ១៩៧១

ប្រធានសមាគម



WHO'S WHO the Most Influential People in Cambodia — BIOGRAPHY

AU CHHOEUN

Au Chhoeun was born on May 11, 1903 in Battambang, the son of Chhoeun In and of Ouk Pel. He studied at Sisowath High School, and later at the Hanoi Faculty of Law. He began as secretary to the French Residence Superior, and later promoted in 1945, to be one of the most prominent Cambodian administrator, with the rank of Voreac Montrey (Minister). He became the Secretary-General of then Principal of Kro-mokars (civil servants).

Political Career: He was Secretary of State for Cults and Religions. He also was the Minister of Interior in the Sisowath Watchhayavong government from July 25, 1947 to February 20, 1948. In February 1948, he was elected Kingdom Councilor, and on October 3, 1948, he was assigned as administrative affairs inspector. On June 25, 1948, he became a member of the first Trade Union Association Committee of the Civil Servants.

He was the Minister of Finance from September 29, 1949 to May 2, 1950, and in Norodom Sihanouk's government (May 3 - May 31, 1950). He held the same position in the Sisowath Monipong government, Minister of Interior of Sisowath Monipong's government (January 1 - March 2, 1951), Minister of Interior and the Information of Oum Chheangsun's government (March 3 - May 13, 1951). He was the Minister for Finance of Oum Chheangsun (May 14 - October 12, 1951). In June 15, 1952, he was named Secretary-general in the Presidency of the Council and Director of Political Affairs, Member of the Council of Regency in 1952, member of the Private Council of the Crown of 1953 to 1954, member of the High-Council of the King of 1958 to 1959.

He was also the Foreign Minister, and the Minister of Cults and Religion of Norodom Sihanouk's government from January 24 to July 28, 1953. Vice-president of the Council, Work and Social action, Art school, minister of religion in the 19th government of Kampuchea of Norodom Sihanouk's (July 29 - November 22, 1953). He was the Minister of State, in charge of the Foreign Affairs and the Conference in the 21st Government of Kampuchea of Norodom Sihanouk (April 7 - 17, 1954). Also was the State Minister, in charge of the National Economy in the 22nd government of Penn Nouth (April 18 - July 31, 1954).

Under Sangkum: Cambodian Ambassador to Great Britain (1963). Under the Khmer Republic: He was the President of the Constitutional Council (1972). He was an adviser of Marshal Lon Nol.

Help us update
*We have gone to a lot of effort to ensure this first edition of "**Who's Who the Most Influential in Cambodia**" is accurate and up-to-date. However, state officials, government members, senators, members of parliament and provincial governors have been changed and replaced so often. Also, general information has changed. If you feel we have got it wrong or left something out, we would like to know, and if you can provide accurate information, so much the better.*

MBN INTERNATIONAL 201

ជីវប្រវត្តិសង្ខេបឯ.ឧ. អូ ឈឿន
ក្នុងសៀវភៅ WHO'S WHO

ពីឆ្វេងមកស្តាំ៖ ទី៣ ឯ.ឧ. អូ ឈឿន(ទីប្រឹក្សា ផ្ទាល់ សេនាប្រមុខ លន់នល់)
ឈរនៅចន្លោះ ឯ.ឧ. ផូ ព្រឿង និង ឯ.ឧ. អុងស៊ឹម ប្រធានព្រឹទ្ធសភាសម័យ
សាធារណ.រដ្ឋខ្មែរ (ឆ្នាំ១៩៧១)។

ឯ,ឧ, **អូ ឈឿង**, បុត្រី នាមអ្នកស្រី ហេងឡុង (នាមដើម **អូ ចំណាង**, កើតឆ្នាំ ១៩៣១),ហ្សាក់គ្រែលក្ខយប្រុស ឯ,ឧ, អូ ឈឿន។ ថតនៅផ្ទះលោកជិតក្រុងប៉ារីស, នៅមហាវិថី វិទ័រអ៊ុយហ្គោ នៅ នើយយីស្សួរសែន

(Bd. Victor Hugo, Neuilly-sur-Seine)។

(រូបថតឆ្នាំ១៩៧៧កម្មសិទ្ធិលោករ៉ូប៉ែរ្ត៍ **ហេង** ចៅប្រុសឯ.ឧ.**អូ ឈឿង**)។

(រូបថត កម្មសិទ្ធិអានីអូ)

សុបិនី អូ *(ហៅអានី) ចៅស្រី* **ឯ,ឧ, អូ ឈឿន** *រស់នៅអាមេរិកសព្វថ្ងៃ ជាបុត្រី លោក* **អូ ចំណិត។**

.

(រូបថតកម្មសិទ្ធិលោករ៉ូប៊ែរហេង)

រ៉ូប៊ែរ្ត៍ ហេង *និងភរិយា* **ភក្តិនី** *(អតីតសាស្ត្រាចារ្យនិងអតីតមន្ត្រីក្រសួងការបរទេសកម្ពុជា ព បុត្រីនាមនាង***សូហ្វីយ៉ា** *ជាចៅទួត ឯ,ឌ,* **អ៊ូ ឈឿន។**

អ្នកស្រី **កោរ រឿយ** (*នាមដើម* **អ៊ូ រឿយ**) *ត្រូវជាប្អូនបង្កើត ឯ,ឧ,* **អ៊ូ ឈឿន**
និងបុត្រធីតា២នាក់។ (កុមារនៅឆ្វេងដៃគឺ **កោរវីរៈ** *និងនៅស្តាំដៃគឺ*
កុមារី កោរ វិជ្ជរី)។

(រូបថតកម្មសិទ្ធិលោក កែរ វីរៈ)
អ្នកស្រី **កោរ រឿយ** (*នាមដើម* **អ៊ូ រឿយ**) *ត្រូវជាប្អូនបង្កើត ឯ,ឧ,* **អ៊ូ ឈឿន**,
អនិច្ចកម្មនៅប្រទេស កាណាដាថ្ងៃទី១៣វិច្ឆិកា២០១៩។

(រូបនេះថតនាបុណ្យពាក់កណ្ដាលសាសនាគឺនៅក្នុងព.ស.២៥០០/
គ.ស.១៩៥៧) (*កម្មសិទ្ធិលោកកែវវីរៈ*)
*ពីឆ្វេងទៅស្តាំ៖ អ្នក*ស្រី អូ វៀង*(ប្អូនស្រីឯ.ឧ* អូ ឈឿន) *លោកយាយ*
អ៊ុកប៊ិល(មាតាឯ.ឧ អូ ឈឿន). *លោកយាយនៅកណ្តាលជាញាតិហើយ*
យាយនៅចុងស្តាំដៃគឺលោកយាយកែវ (ប្អូនស្រីលោកតា ស៊ូ អូ បិតាឯ.ឧ
អូ ឈឿន។